# កម្ពុជា ៖ ភូមិអ្នកក្រីក្រកើតអេដស៍ រំលោភសិទ្ធិ

*ក្រុមធ្វើការប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍និងជំងឺអេដស៍ និងក្រុមយុត្តិធម៌សង្គម អំពាវនាវឲ្យរដ្ឋាភិបាល បញ្ឈប់ការបណ្តេញចេញនូវគ្រួសារដែលរងផលប៉ះពាល់ដោយមេរោគអេដស៍*

(ថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០០៩) - អង្គការអន្តរជាតិប្រយុទ្ធប្រឆាំងនិងជំងឺអេដស៍និងអង្គការយុត្តិធម៌សង្គម និងអ្នកជំនាញជាង ១០០ បានមានប្រសាសន៍នៅថ្ងៃនេះ ក្នុងលិខិតរួមមួយផ្ញើជូនទៅនាយករដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងសុខាភិបាលនៃប្រទេសកម្ពុជាថា រដ្ឋាភិបាលកម្ពុជាត្រូវតែដោះស្រាយល័ក្ខខ័ណ្ឌប្រកបដោយគ្រោះថ្នាក់ជាបន្ទាន់ ក្នុងភូមិអ្នកក្រីក្រកើតអេដស៍ដែលរដ្ឋាភិបាលបានបង្កើតឡើង និងត្រូវបញ្ឈប់ជាបន្ទាន់នូវការបញ្ជូនគ្រួសារ ដែលរងផលប៉ះពាល់ដោយមេរោគអេដស៍ទៅកាន់ទីតាំងភូមិនោះ។

ក្នុងខែមិថុនា ឆ្នាំ២០០៩ — រដ្ឋាភិបាលកម្ពុជា បានជម្លៀសដោយបង្ខំនូវគ្រួសារដែលរងផលប៉ះពាល់ដោយមេរោគអេដស៍ចំនួន ២០ គ្រួសារ ដែលកំពុងរស់នៅបូរីកីឡាដែលជាកន្លែងអភិវឌ្ឍលំនៅដ្ឋាននៅក្រុងភ្នំពេញ ទៅកាន់តំបន់តាំងលំនៅដ្ឋានមិនទៅតាមបទដ្ឋានមួយនៅឯទួលសំបូរ ដែលជាតំបន់ដាច់ស្រយាលមានចម្ងាយ ២៥ គីឡូម៉ែត្រពីទីក្រុង។ ចំនួន ២០ គ្រួសារផ្សេងទៀតត្រូវបានរដ្ឋាភិបាលបញ្ជូនទៅកាន់ទីនោះទៀត នៅថ្ងៃទី ២៣ ខែកក្កដា។ គ្រួសារទាំងនោះ ត្រូវបានគេឱ្យតាំងលំនៅក្នុងជម្រកស័ង្កសីពណ៌បៃតងអង្កាញ់ៗ ដែលដុតឆ្អើរដោយកំដៅព្រះអាទិត្យនៅពេលថ្ងៃ និងមិនមានចរន្តទឹកស្អាតនិងអានាម័យគ្រប់គ្រាន់។ មិនឆ្ងាយពីទីនោះប៉ុន្មានម៉ែត្រឡើយ មានផ្ទះថ្មដែលមានគុណភាពខ្ពស់ត្រូវបានគេសាងសង់ឡើង ដោយមានជំនួយពីក្រុមមិនរកកម្រៃ សម្រាប់គ្រួសារដែលគ្មានផ្ទះសម្បែងដែលនឹងត្រូវមកតាំងលំនៅជាថ្មីនៅទួលសំបូរ។ មុនពេលគេឱ្យគ្រួសារដែលរងផលប៉ះពាល់ដោយមេរោគអេដស៍មកតាំងលំនៅកន្លែងនេះ អ្នកស្រុកតំបន់នេះបានហៅជម្រកពណ៌បៃតងនេះថាជា “ភូមិអ្នកកើតអេដស៍” រួចទៅហើយ។

ស៊ីបាន ភូវ៉ៃឡាផាមពីអង្គការ Asia-Pacific Network of People Living with HIV/AIDS ជាបណ្តាញអ្នករស់នៅជាមួយមេរោគអេដស៍និងជំងឺអេដស៍អាស៊ីប៉ាស៊ីហ្វិច បានមានប្រសាសន៍ថា “ការដាក់ឱ្យអ្នករស់នៅជាមួយមេរោគអេដស៍រស់នៅផ្តុំគ្នាក្នុងលំនៅដាច់ពីគេពីឯង ឆ្ងាយពីមន្ទីរពេទ្យ សេវាគាំទ្រនិងការងារ បង្ហាញថារដ្ឋាភិបាលបានបង្កើតភូមិអ្នកកើតអេដស៍យ៉ាងពិតប្រាកដណាស់។ វាពិបាកនឹងយល់អំពីរបៀបដែលរដ្ឋាភិបាលបាននូវការទទួលស្គាល់ជាអន្តរជាតិចំពោះកិច្ចប្រឹងប្រែងបង្ការមេរោគអេដស៍របស់ខ្លួន ខណៈពេលដែលរដ្ឋាភិបាលនេះ ឥតមានធម៌មេត្តាអើពើរចំពោះសិទ្ធិជាមូលដ្ឋានរបស់អ្នករស់នៅជាមួយមេរោគដស៍អេដស៍។”

អង្គការនិងបុគ្គលមួយចំនួនដែលមានមូលដ្ឋាននៅតំបន់អាស៊ីប៉ាស៊ីហ្វិច បានចុះហត្ថលេខាទៅលើលិខិតចូលរួម ក្នុងនាមជាបុគ្គលនិងជាក្រុម ពីបណ្តាប្រជាជាតិជាច្រើន ចាប់តាំងពីប្រទេសកកាដា សហរដ្ឋអាមេរិក រហូតដល់ប្រទេសឥណ្ឌារ និងតង់ហ្សានា។

លិខិតនោះបញ្ជាក់ថា ស្ថានភាពរស់នៅឯទួលសំបូរ មិនស្របតាមបទដ្ឋានអប្បបរមាអន្តរជាតិ សម្រាប់ការតាំងលំនៅក្នុងគ្រាអាសន្នជាបណ្តោះអាសន្នឡើយ។ ជម្រកត្រូវបានគេសង់ជាប់នឹងលូទឹកស្អុយដែលគ្មានគម្រប ដោយមានផ្តល់អណ្តូងសាធារណៈតែមួយគត់សម្រាប់គ្រួសារទាំងអស់។ ពួកគេរស់នៅផ្ដុំគ្នាក្នុងជម្រកស័ង្កសីដែលមិនសូវមានខ្យល់ចេញចូល ជាកន្លែងដែលមានកំដៅដ៏ខ្លាំងនៅពេលរសៀល ដែលជាញឹកញយធ្វើឱ្យពួកគេមិនអាចនៅក្នុងបន្ទប់បាន និងធ្វើឱ្យពួកគេព្រួយបារម្ភអំពីការខូចថ្នាំប្រឆាំងមេរោគអេដស៍របស់ពួកគេ។

Kevin Moody តំណាងអង្គការ Global Network of People Living with HIV ជាបណ្តាញពិភពលោករបស់អ្នករស់នៅជាមួយមេរោគអេដស៍ មានប្រសាសន៍ថា ‘‘លក្ខខណ្ឌរស់នៅឯទួលសំបូរបង្ករឱ្យ មានការប្រថុយនឹងគ្រោះថ្នាក់ខាងសុខភាព យ៉ាងធ្ងន់ធ្ងរសម្រាប់គ្រួសារដែលរស់នៅទីនោះ។ អ្នករស់នៅជាមួយមេរោគអេដស៍ងាយសម្របសម្រួលទៅនឹង ប្រព័ន្ធស៊ាំនឹងរោគ និងងាយរងគ្រោះថ្នាក់ណាស់។ សម្រាប់ពួកគេល័ក្ខខ័ណ្ឌរស់នៅមិនស្របតាមបទដ្ឋាននេះ អាច មានន័យស្មើនិងទោសប្រហារជីវិត ឬលិខិតទៅកាន់មន្ទីរពេទ្យ។’’

អង្គការទាំងនោះ បានសម្តែងកង្វល់យ៉ាងជ្រាលជ្រៅផងដែរ អំពីការរើសអើងប្រឆាំងនិងគ្រួសារដែលរងផលប៉ះពាល់ដោយមេរោគអេដស៍ ក្នុងដំណើការជ្រើសរើសនិងការដាក់តាំទីលំនៅ សម្រាប់ការតាំងលំនៅដ្ឋាននៅនឹងកន្លែងដែលកំពុងសាងសង់នៅឯបូរីកីឡា។ បន្ទាប់ពីរយៈពេលពីរឆ្នាំនៃការប្រាលចោលសិទ្ធិទទួលបានលំនៅដ្ឋាននៅនឹងកន្លែងរបស់គ្រួសារដែលរងផលប៉ះពាល់ដោយមេរោគអេដស៍មក ឥឡូវនេះអាជ្ញាធរនិយាយថា យ៉ាងហោចណាស់មាន ១១ គ្រួសារដែលរងផលប៉ះពាល់ដោយមេរោគអេដស៍ ដែលនឹងត្រូវបញ្ជូនទៅទួលសំបូរកាលពីពេលមុន មានសិទ្ធិទទួលបានលំនៅដ្ឋាននៅនឹងកន្លែង។ គ្រួសារទាំងនោះស្ថិតនៅបូរីកីឡា ប៉ុន្តែពួកគេនៅតែកំពុងរងចាំលំនៅដ្ឋានដែលអាជ្ញាធរបានសន្យាឱ្យ។

កំណើនតម្លៃអចលនទ្រព្យនៅក្នុងរាជធានីរបស់ប្រទេសកម្ពុជា បានធ្វើឱ្យគ្រួសារក្រីក្រជាយក្រុងជាច្រើនពាន់នាក់ទទួលរងគ្រោះដោយការបណ្តេញចេញដោយបង្ខំ ដើម្បីត្រួសត្រាយផ្លូវសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច។ ការអភិវឌ្ឍតំបន់បូរីកីឡា ត្រូវបានយល់ព្រមនៅក្នុងឆ្នាំ២០០៣ ដោយមានការយោគយល់ថា អ្នកអភិវឌ្ឍនឹងសង់លំនៅដ្ឋានថ្មីនៅនឹង

កន្លែង ដែលតាមគម្រោងនោះ គឺសម្រាប់អ្នកទាំងឡាយដែលមិនមានកន្លែងរស់នៅ។ ក៏ប៉ុន្តែ ដោយមានការលើកលែងខ្លះ គ្រួសារដែលរងផលប៉ះពាល់ដោយមេរោគអេដស៍ ដែលមិនមានកន្លែងរស់នៅតាំងពីដើមមក មិនត្រូវបានគេជ្រើសរើសឱ្យមានសិទ្ធិទទួលលំនៅដ្ឋាននេះទេ។

នៅពេលរស់នៅឯបូរីកីឡា ប្រជាពលរដ្ឋទាំងនេះបានធ្វើការងារពេលថ្ងៃជាកម្មករ អ្នករត់ម៉ូតូឌុប អ្នកបោសសម្អាត និងអ្នកកាត់ដេរ។ ឥឡូវនេះ ភាគច្រើនមិនមានសង្ឃឹមថាមានការងារធ្វើនៅទួលសំបូរ ឬក្បែរទួលសំបូរនោះឡើយ។ ស្ថានភាពសេដ្ឋកិច្ចរបស់ពួកគេ កាន់តែអាក្រក់ទៅៗ ដោយសារការធ្វើដំណើរត្រឡប់ទៅភ្នំពេញធ្វើការងារ ឬទៅមន្ទីរពេទ្យដែលការធ្វើដំណើរនេះមានតម្លៃប្រហាក់ប្រហែលនឹង ៥ ដុល្លារអាមេរិក — សម្រាប់គ្រួសារដែលប្រឹងរកបានត្រឹមតែ ១ ដុល្លារប្រាំកាក់ទៅ ៣ ដុល្លារប៉ុណ្ណោះក្នុងមួយថ្ងៃ។

រ៉េបេកា ឡេហ្វ៊ីពីអង្គការ Human Rights Watch ដែលជាអង្គការឃ្លាំមើលសិទ្ធិមនុស្ស បានមានប្រសាសន៍ថា “រដ្ឋាភិបាលកម្ពុជា ត្រូវបញ្ចប់ការរើសអើងនៅពេលឥឡូវនេះ ហើយត្រូវបង្កើតឱ្យមាននីតិវិធីចំហនិងយុត្តិធម៌មួយ សម្រាប់ទាំងអស់គ្នាក្នុងការទទួលបានលំនៅដ្ឋាន និងសេវាដែលពួកគេត្រូវការ។ អ្នករស់នៅជាមួយមេរោគអេដស៍ - ក៏ដូចអ្នកដទៃទៀតដែរ — ត្រូវមានល័ក្ខខ័ណ្ឌលំនៅដ្ឋានសមរម្យ ដែលមិនគម្រាមកំហែងដល់សុខភាពរបស់ពួកគេ និងមធ្យោបាយរកស៊ីចិញ្ចឹមជីវិតរបស់ពួកគេ ដើម្បីឱ្យពួកគេអាចចិញ្ចឹមខ្លួនឯង និងគ្រួសាររបស់ពួកគេ។”

ក្រុមទាំងនេះ ស្នើរសុំឱ្យរដ្ឋាភិបាលកម្ពុជា :

* បញ្ឈប់ការបញ្ជូនគ្រួសារដែលរងផលប៉ះពាល់ដោយមេរោគអេដស៍ទៅកាន់កន្លែងទួលសំបូរ
* ធ្វើឱ្យស្ថានភាពនៅទួលសំបូរមានភាពប្រសើរឡើង ស្របទៅនឹងបទដ្ឋានអប្បបរដើម្បីលំនៅដ្ឋានសមរម្យ អនាម័យ និងទឹកស្អាត
* ធានាឱ្យមានសិទ្ធិពេញលេញដើម្បីទទួលបានសេវាសុខាភិបាល រួមទាំងការព្យាបាលថ្នាំប្រឆាំងមេរោគអេដស៍ ការព្យាបាលជំងឺឱកាសនិយម ការថែទាំសុខភាពបឋម និងការថែទាំតាមផ្ទះ
* ធ្វើការជាមួយទីភ្នាក់ងារពាក់ព័ន្ធ និងប្រឹក្សាជាមួយគ្រួសារដែលស្ថិតនៅទួលសំបូរជាស្រេចហើយនោះ ដើម្បីដោះស្រាយកង្វល់រយៈឆាប់និងរយៈពេលយូរស្តីពីលំនៅដ្ឋាន សុខភាព សុវត្ថិភាព និងការងារ និងការដាក់បញ្ចូលពួកគេទៅក្នុងសង្គមឡើងវិញ ក្នុងវិធីមួយដែលការពារសិទ្ធិនិងការចិញ្ចឹមជីវិតរបស់ពួកគេ និង
* ធ្វើឱ្យមាននីតិវិធីជ្រើសរើសប្រកបដោយតម្លាភាពនិងយុត្តិធម៌ ដើម្បីកំណត់សិទ្ធិទទួលបានលំនៅដ្ឋាននៅនឹងកន្លែងឯបូរីកីឡា និងអនុញ្ញាតិគ្រួសារដែលមានសិទ្ធិទទួលលំនៅដ្ឋាន ចូលទៅនៅក្នុងលំនៅដ្ឋានឆាប់ៗនេះ (រួមទាំង

១១ គ្រួសារដែលរងផលប៉ះពាល់ដោយមេរោគអេដស៍ដែលមានការយល់ព្រមហើយផងដែរ) ។ សម្រាប់អ្នកដែលមិនមានសិទ្ធិទទួលលំនៅដ្ឋាននៅនឹងកន្លែង អាជ្ញាធរត្រូវតែផ្តល់លំនៅដ្ឋានផ្សេងទៀតដល់ពួកគេឱ្យបានសមរម្យ ។

អាឌីធីសាម៉ា ពីអង្គការ International Treatment Preparedness Coalition ជាអង្គការចម្រុះឃ្លាំមើលការប្រព្រឹត្តជាអន្តរជាតិ បាននិយាយថា “ការរស់នៅជាមួយមេរោគអេដស៍ប្រកបដោយសេចក្តីថ្លៃថ្នូរមានអត្ថន័យច្រើនជាងការទទួលបានការព្យាបាលដោយថ្នាំប្រឆាំងមេរោគអេដស៍ ។ វាមានន័យថា គ្រួសារទាំងនេះត្រូវមានបរិយាកាសប្រកបដោយសុខភាពជាមួយនិងអាហារូបត្ថម្ភគ្រប់គ្រាន់ អនាម័យត្រឹមត្រូវ និងការថែទាំបន្ត ដែលជួយដោះស្រាយដល់ផលវិបាកខាងសង្គម ចិត្តសាស្រ្ត ផ្លូវច្បាប់ និងខាងសេដ្ឋកិច្ចនៃការរស់នៅជាមួយមេរោគអេដស៍ ។”

**ដើម្បីអានលិខិតរួមពីក្រុមនានាដែលបានផ្ញើជូនទៅកាន់លោកនាយករដ្ឋមន្រ្តី និងរដ្ឋមន្រ្តីក្រសួងសុខាភិបាល កម្ពុជា សូមចូលទៅមើល :**

* http://www.hrw.org/node/84642 (ភាសាខ្មែរ)

* http://www.hrw.org/node/84641 (English)

**ដើម្បីមើលរូបភាពបង្ហាញរបស់អង្គការ Human Rights Watch ជាអង្គការឃ្លាំមើលសិទ្ធិមនុស្ស ដែលបង្ហាញពីគ្រួសារដែលរងផលប៉ះពាល់ដោយមេរោគអេដស៍នៅបូរីកីឡា និងទួលសំបូរ សូមចូលទៅមើល :** http://www.hrw.org/en/features/cambodia-aids-colony-violates-rights